ថ្ងៃទី26 ខែមិថុនា ឆ្នាំរេយវ៉ា 2(ឆ្នាំ2020)
(បានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី7 ខែតុលា ឆ្នាំ2022)
ទីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន

**ចំពោះអ្នកដែលមានលក្ខណៈសម្បត្តិស្នាក់នៅអចិន្ត្រៃយ៍ ដែលមានការពិបាកនឹងចូលមកប្រទេសជប៉ុនក្នុងកម្លុងពេលដែលការអនុញ្ញាតឱ្យចូលវិញនៅមានសុពលភាព ដោយសារឥទ្ធិពលនៃជម្ងឺឆ្លងកូវីដ១៩**

ដោយសារឥទ្ធិពលនៃជម្ងឺឆ្លងកូវីដ១៩ អ្នកដែលមានលក្ខណៈសម្បត្តិស្នាក់នៅអចិន្ត្រៃយ៍ ដែលមានការពិបាកនឹងចូលមកប្រទេសជប៉ុនវិញ ក្នុងកម្លុងពេលដែលការអនុញ្ញាតឱ្យចូលវិញ ឬកម្លុងពេលដែលចាត់ទុកថាមានការអនុញ្ញាតឱ្យចូលវិញនៅមានសុពលភាព អាចចូលមកប្រទេសជប៉ុនវិញបានតាមវិធីខាងក្រោមនេះ (※1) ដូច្នេះ សូមអញ្ជើញទៅពិគ្រោះនឹងស្ថានទូត ឬកុងស៊ុលជប៉ុននៅកន្លែងដែលលោកអ្នករស់នៅ។

(1) ករណីដែលកម្លុងពេលដែលការអនុញ្ញាតឱ្យចូលវិញអស់សុពលភាព ឬក្នុងករណីដែលមានការពិបាកនឹងចូលមកវិញក្នុងកម្លុងពេលមានសុពលភាព

មានករណីដែលអាចសុំពន្យារកម្លុងពេលសុពលភាពនៃការចូលមកវិញបាន នៅតាមស្ថានទូត ឬកុងស៊ុលជប៉ុននៅកន្លែងដែលលោកអ្នករស់នៅបាន។

[ កម្លុងពេលដែលអាចពន្យារបានគឺ យ៉ាងវែង 1ឆ្នាំ ដោយគិតពីថ្ងៃដែលកម្លុងពេលមានសុពលភាពបានដាច់។ ]

ក្នុងករណីដែលកម្លុងពេលដែលការអនុញ្ញាតឱ្យចូលវិញមានសុពលភាពត្រូវបានពន្យារ សូមចូលប្រទេសជប៉ុនវិញក្នុងកម្លុងពេលពន្យារថ្មីនោះ។ បើសិនជាមិនអាចពន្យារបាន សូមចូលមកវិញដោយវិធីទី(2) ។

(2) ករណីដែលកម្លុងពេលដែលចាត់ទុកថាមានការអនុញ្ញាតឱ្យចូលវិញមានសុពលភាពបានកន្លងផុត (រួមទាំងករណីដែលមិនអាចធ្វើតាមចំណុច(1)បាន)

[ នេះអនុវត្តន៍ចំពោះជនបរទេស ដែលកាលបរិច្ឆេទផុតកំណត់សុពលភាពនៃកម្លុងពេលអនុញ្ញាតឱ្យចូលវិញ ឬកម្លុងពេលដែលចាត់ទុកថាមានការអនុញ្ញាតឱ្យចូលវិញ គឺនៅចន្លោះថ្ងៃទី1 ខែមករា ឆ្នាំ2020 នឹងថ្ងៃទី30 ខែមេសា ឆ្នាំ2023។ ]

សូមអញ្ជើញទៅដាក់ពាក្យសុំទិដ្ឋាការ "អ្នកស្នាក់នៅជាប់លាប់" នៅស្ថានទូត ឬស្ថានកុងស៊ុលជប៉ុននៃប្រទេសដែលអ្នកកំពុងស្នាក់នៅឱ្យបានមុនឬត្រឹមថ្ងៃទី30 ខែមេសា ឆ្នាំ2023។

នៅពេលដែលបានទទួលទិដ្ឋាការហើយ អ្នកនឹងអាចធ្វើនីតិវិធីចាំបាច់ ដើម្បីចូលប្រទេសជប៉ុនជាថ្មីក្នុងនាមជា "អ្នកស្នាក់នៅអចិន្ត្រៃយ៍" នៅអាកាសយានដ្ឋានណាមួយក្នុងប្រទេសជប៉ុននៅពេលមកដល់។

*1 ស្តីពីឯកសារចាំបាច់ក្នុងការធ្វើនីតិវិធី (1) និង (2) សូមមើលគេហទំព័ររបស់ក្រសួងការបរទេសខាងក្រោមនេះ។

[https://www.mofa.go.jp/about/emb_cons/mofaserv.html (បើកផបសាយរបស់ក្រសួងការបរទេស)](https://www.mofa.go.jp/about/emb_cons/mofaserv.html)

*2 ប្រសិនបើជនបរទេសដែលជាមុខសញ្ញានៃវិធានការនេះ បានចូលមកប្រទេសជប៉ុនក្រោមលក្ខណៈសម្បត្តិស្នាក់នៅក្រៅពី "អ្នកស្នាក់នៅអចិន្ត្រៃយ៍" យោងតាម (1) ឬ (2) ខាងក្រោម ដោយមិនប្រើវិធានការនេះ ហើយប្រសិនបើជនបរទេសនោះដាក់ពាក្យសុំការអនុញ្ញាតស្នាក់នៅអចិន្ត្រៃយ៍ក្នុងអំឡុងពេល6ខែក្រោយពេលចូលប្រទេសជប៉ុន ជននោះនឹងត្រូវបានពិនិត្យផ្អែកលើពាក្យស្នើសុំការអនុញ្ញាតស្នាក់នៅអចិន្ត្រៃយ៍ដែលបានដាក់ស្នើ រួមមាន សំណូមពាក្យ (ទម្រង់ឯកសារយោងទី1 មានផ្តល់ជូនដោយឡែក) និងឯកសារចម្លងនៃប័ណ្ណស្នាក់នៅមុន។ (អាចមានករណីទាមទារឱ្យដាក់ឯកសារផ្សេងទៀតតាមការចាំបាច់។)

(1) ប្រសិនបើជនបរទេសបានចូលប្រទេសជប៉ុនក្រោមលក្ខណៈសម្បត្តិស្នាក់នៅក្រៅពី "អ្នកស្នាក់នៅអចិន្ត្រៃយ៍" ក្នុងកំឡុងពេលសុពលភាពនៃទិដ្ឋាការដែលបានស្នើសុំមុនឬត្រឹមថ្ងៃទី31 ខែតុលា ឆ្នាំ2023

(2) ប្រសិនបើជនបរទេសបានចូលប្រទេសជប៉ុនមុនឬត្រឹមថ្ងៃទី31 ខែតុលា ឆ្នាំ2023 ដោយគ្មានទិដ្ឋាការ និងក្រោមលក្ខណៈសម្បត្តិស្នាក់នៅក្រៅពី "អ្នកស្នាក់នៅអចិន្ត្រៃយ៍"

ម្យ៉ាងទៀត សូមកត់សំគាល់ថា ថ្លៃសេវា 8,000 យ៉េនក្នុងម្នាក់ត្រូវបានតម្រូវឱ្យបង់ ដើម្បីទទួលបានការអនុញ្ញាតស្នាក់នៅអចិន្ត្រៃយ៍ក្រោយពីចូលប្រទេសជប៉ុន។

សូមកត់សំគាល់ផងដែរថា ក្នុងករណីដែលជនបរទេសដាក់ពាក្យសុំការអនុញ្ញាតស្នាក់នៅអចិន្ត្រៃយ៍ក្រោយពេល6ខែ បន្ទាប់ពីបានចូលប្រទេសជប៉ុន គឺចាំបាច់ត្រូវដាក់ឯកសារបញ្ជាក់ដូចគ្នានឹងតម្រូវការក្នុងការស្នើសុំការអនុញ្ញាតស្នាក់នៅអចិន្ត្រៃយ៍ធម្មតា។

ជនបរទេសដែលបានក្លាយទៅជា អ្នកស្នាក់នៅរយៈពេលមធ្យមទៅវែង តាមរយៈការអនុញ្ញាតស្នាក់នៅអចិន្ត្រៃយ៍ ចាំបាច់ត្រូវទៅជូនដំណឹងដល់សាលាក្រុង ស្រុក ឃុំ ភូមិនៃលំនៅដ្ឋានដែលគាត់នឹងស្នាក់នៅ ក្រោយទទួលបានការអនុញ្ញាតស្នាក់នៅអចិន្ត្រៃយ៍។